**បទឧទ្ទេសនាម**

**ស្តីពីខ្លឹមសារសង្ខេបនៃរដ្ឋធម្មនុញ្ញ**

**នៃព្រះរាជាណាចក្រកម្ពុជា និងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ**

I-**ទស្សនទានទូទៅនៃរដ្ឋធម្មនុញ្ញ**

**១-រដ្ឋធម្មនុញ្ញជាអ្វី** ?

រដ្ឋធម្មនុញ្ញជាច្បាប់គោល ឬ ជាច្បាប់កំពូលរបស់ប្រទេសនីមួយៗ ។ ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តទាំងអស់ត្រូវស្របតាមរដ្ឋធម្មនុញ្ញ បើពុំនោះទេនឹងត្រូវប្រកាសថា អធម្មនុញ្ញភាព ។

**២-សញ្ញាណនៃរដ្ឋធម្មនុញ្ញគឺអ្វីខ្លះ** ?

ក-រដ្ឋធម្មនុញ្ញជាកិច្ចសន្យានៃការស្មោះត្រង់នឹងគ្នា។ ស្តេចអង់គ្លេសចុះកិច្ចសន្យាជាមួយអ្នកស្មើសក្តិគ្នា ( Les paires ) បង្កើតបានជាកតិកាសញ្ញាធំ ( La grande charte ) ពី គ .ស. ១២១៥ មាន ៦០ មាត្រា ។ គេចាត់ទុកជារដ្ឋធម្មនុញ្ញលើកដំបូងលើពិភពលោក ។

ខ-រដ្ឋធម្មនុញ្ញជាកិច្ចសន្យានៃសង្គម ( Contrat social ) មានន័យថា ជាកិច្ចព្រមព្រៀងរវាងប្រជារាស្ត្រ និង ប្រជារាស្ត្រដើម្បីបង្កើតអំណាចនយោបាយ ។

គ-រដ្ឋធម្មនុញ្ញ គឺជាលក្ខន្តិកៈនៃអំណាច ។ តើមានអំណាចអ្វីខ្លះ ? ហើយអំណាចនីមួយៗ មានសមត្ថកិច្ចយ៉ាងណា ? តើមានការបែងចែកអំណាចដាច់ពីគ្នាឬទេ ? មានតុល្យភាពអំណាចឬទេ ?

ឃ-រដ្ឋធម្មនុញ្ញ គឺជាលក្ខណៈនៃទស្សនវិជ្ជានយោបាយ ។ ការកំណត់ចក្ខុវិស័យនៃសង្គម ។

ង-រដ្ឋធម្មនុញ្ញគឺជាលក្ខន្តិកៈសម្រាប់អ្នកគ្រប់គ្រងគេ រដ្ឋធម្មនុញ្ញបានបង្កើតអំណាចសាធារណៈ កំណត់អំពីសមត្ថកិច្ច និង ចាត់ចែងការទាក់ទងរវាងអំណាចសាធារណៈទាំងនោះ ។

**៣-រដ្ឋធម្មនុញ្ញដំបូងនៃប្រទេសខ្លះ ក្នុងពិភពលោក**

- គ.ស ១២១៥ កតិការសញ្ញាធំ ឬ ធម្មនុញ្ញធំ (La grande charte) មាន ៦០ មាត្រា ។ ស្តេចអង់គ្លេសបានចុះកិច្ចសន្យាជាមួយអ្នកស្មើសក្តិគ្នា ( Les paires ) ។
- គ.ស ១៣៥៦ ស្តេច Charles IV de Luxembourg ប្រកាសឲ្យប្រើ Bull d' or គឺជារដ្ឋធម្មនុញ្ញនៃ Saint Empire ( ឬអាល្លឺម៉ង់សម័យនោះ ) ។
- គ.ស ១៧៧៦ រដ្ឋធម្មនុញ្ញនៃ រដ្ឋវៀស៊ីនីញ៉ា ( VIRGINA ) អាមេរិក មានកំណត់អំពីសិទ្ធិលើកដំបូង ហើយជះឥទ្ធិពលដល់បដិវត្តបារាំង ១៧៨៩ ។
- គ.ស ១៧៨៧ រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ប្រើពីកកើតមកបច្ចុប្បន្ន អាយុ ២៣៦ ឆ្នាំហើយ ។ Geoge Washington ជាប្រធានាធិបតីទី១ នៃសហរដ្ឋអាមេរិក ។
- ២៨ សីហា ១៧៨៩ សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្ស និង សិទ្ធិពលរដ្ឋ មាន ១៧ មាត្រា ដោយបដិវត្តបារាំង ហើយសេចក្តីថ្លែងការណ៍នេះជាមូលដ្ឋាននៃការធ្វើរដ្ឋធម្មនុញ្ញបារាំង ។
- ០៣ កញ្ញា ១៧៩១ រដ្ឋធម្មនុញ្ញទី១ របស់ប្រទេសបារាំង ។

- គ.ស ១៨១២ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ អេស្ប៉ាញ ។
- គ.ស ១៨១៤ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ ន័រវែស ។ ឆ្នាំ២០១៤ ន័រវែស ធ្វើបុណ្យខួប គម្រប់ ២០០ឆ្នាំ ។
- គ.ស ១៨៣១ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ បែលហ្ស៊ិក ។

II-**រដ្ឋធម្មនុញ្ញនាំទឡ្ហាយនៃកម្ពុជា**

១-រដ្ឋធម្មនុញ្ញប្រទេសកម្ពុជាប្រកាសឲ្យប្រើថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ១៩៤៧ មាន ១២ ជំពូក ១២២ មាត្រា មានអានុភាពអនុវត្តរហូតដល់រដ្ឋប្រហារថ្ងៃទី ១៨ ខែ មីនា ឆ្នាំ១៩៧០ ។

២-រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរប្រកាសឲ្យប្រើថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ១៩៧២ មាន ១១ ជំពូក ១២១ មាត្រា ។

៣-រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យប្រកាសឲ្យប្រើថ្ងៃទី ០៥ ខែ មករា ឆ្នាំ១៩៧៦ មាន ១៦ ជំពូក ២១ មាត្រា ។

៤-រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាប្រកាសឲ្យប្រើថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ១៩៨១ មាន ១០ ជំពូក ៩៣ មាត្រា ។

៥-រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជាប្រកាសឲ្យប្រើថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ១៩៩១ មាន ១០ ជំពូក ៩៣ មាត្រា ។

៦-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាប្រកាសឲ្យប្រើថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ១៩៩៣ បានធ្វើវិសោធនកម្ម ០៧ លើក មាន ១៧ ជំពូក ១៦០ មាត្រា និង ច្បាប់ធម្មនុញ្ញបន្ថែមមួយ មាន ៧ មាត្រា ប្រកាសឲ្យប្រើថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០៤ ។

III-**អំពីខ្លឹមសាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣**

**ជំពូកទី១ អំពីអធិបតេយ្យ** មាន ០៦ មាត្រា គឺពីមាត្រា ០១ ដល់ មាត្រា ០៦ ដែលចែងជាអាទិ៍ថា ប្រទេសកម្ពុជាជាព្រះរាជាណាចក្រកម្ពុជាដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជាជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍មិនចូលបក្សសម្ព័ន្ធ និងជារដ្ឋដែលមិនអាចបំបែកបាន ។

**ជំពូកទី២ អំពីព្រះមហាក្សត្រ** មាន ២៤ មាត្រា គឺពីមាត្រា ០៧ ដល់ មាត្រា ៣០ ថ្មី ដែលចែងជាអាទិ៍ថា ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។ ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ហើយមិនអាចនរណារំលោភបំពានបានឡើយ ។ របបរាជានិយមកម្ពុជាជារបបជ្រើសតាំង ។ ព្រះមហាក្សត្រទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទសម្រាប់គ្រងរាជសម្បត្តិឡើយ ។ ព្រះមហាក្សត្រថ្មីត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ដែលមានសមាសភាពកំណត់មាត្រា ១៣ ថ្មី នៃជំពូកនេះ ចែងអំពីសមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិ ។

ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ... មិនអាចសុំកែប្រែបានជាដាច់ខាត ។

ព្រះមហាក្សត្រទ្រង់ទាក់ទងជាមួយព្រឹទ្ធសភានិងរដ្ឋសភាដោយព្រះរាជសារ។ ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រីនិងគណៈរដ្ឋមន្ត្រី ។ តាមសេចក្ដីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ដលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ឯកអគ្គរាជទូត ប្រេសិតវិសាមញ្ញនិងពេញសមត្ថភាព ។

តាមសេចក្ដីស្នើរបស់ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ដលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្ដូរ ឬដកចៅក្រម ។

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ដលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនិងច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និង ទ្រង់ឡាយព្រះហស្ដលេខាលើព្រះរាជក្រឹត្យតាមសេចក្ដីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ព្រះមហាក្សត្រទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ។ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើងដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ ព្រះមហាក្សត្រទ្រង់ទទួលសារតាំងឯកអគ្គរដ្ឋទូត ឬប្រេសិតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសក្រៅ ។ ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោសនិងលើកលែងទោស ។ ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្ដីទី ។

**<u>ជំពូកទី៣</u> អំពីសិទ្ធិ និង ករណីយកិច្ចប្រជាពលរដ្ឋខ្មែរ** មាន ២០ មាត្រា គឺពីមាត្រា ៣១ ដល់មាត្រា ៥០ ។ ជំពូកនេះមានចែងជាអាទិ៍ថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និង គោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។ ទោសប្រហារជីវិតត្រូវបានលុបបំបាត់ចោល រីឯការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិច្បាប់ ។

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម សហជីព និងគណបក្សនយោបាយ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ការរើសអើងប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល ។ បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និង គ្រួសារ ។

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្ដីពីកុមារ ។ ទន្ទឹមនឹងសិទ្ធិដែលមានចែងក្នុងជំពូកនេះ ប្រជាពលរដ្ឋខ្មែរមានករណីយកិច្ចគោរពរដ្ឋធម្មនុញ្ញនិងគោរពច្បាប់ ព្រមទាំងមានករណីយកិច្ចរួមចំណែកកសាងប្រទេសជាតិ និង ការពារមាតុភូមិ ព្រមទាំងគោរពគោលការណ៍អធិបតេយ្យជាតិ និង លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

**<u>ជំពូកទី៤</u> អំពីរបបនយោបាយ** មាន ០៥ មាត្រា គឺពីមាត្រា ៥១ ថ្មី ដល់ មាត្រា ៥៥ ដែលចែងជាអាទិ៍ថា ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និង សាលាជម្រះក្តី ។ អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ ។

ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។

**<u>ជំពូកទី៥</u> អំពីសេដ្ឋកិច្ច** មាន ០៩ មាត្រា គឺពីមាត្រា ៥៦ ដល់ មាត្រា ៦៤ ដែលចែងថា ព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី ។

រដ្ឋជំរុញការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាលដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន.។

រដ្ឋយកចិត្តទុកដាក់ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផលជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល ។

រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានកម្រិតសមរម្យ។

**<u>ជំពូកទី៦</u> អំពីអប់រំ វប្បធម៌ និង សង្គមកិច្ច** មាន ១១ មាត្រា គឺពីមាត្រា ៦៥ ដល់ មាត្រា ៧៥ ដែលចែងជាអាទិ៍ថា រដ្ឋត្រូវការពារ និង លើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កម្រិត និង ត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។ រដ្ឋមានកាតព្វកិច្ចថែរក្សា និង ពង្រីកវប្បធម៌ជាតិ ព្រមទាំងថែរក្សា និងការពារប្រាសាទបុរាណ វត្ថុសិល្បៈបុរាណ និង កែលំអរមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ ។

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ប្រជារាស្ត្រក្រីក្រត្រូវបានទទួលពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ ។

**<u>ជំពូកទី៧</u> អំពីរដ្ឋសភា** មាន ២៣ មាត្រា គឺពីមាត្រា ៧៦ ដល់ មាត្រា ៩៨ ថ្មី ដែលចែងថា រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០រូប តាមការជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និង តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។ នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង ។ តំណាងរាស្ត្រក្នុងរដ្ឋសភាជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា មានន័យថា តំណាងរាស្ត្ររូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ។

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ។ តំណាងរាស្ត្រមានសិទ្ធិស្នើផ្តួចផ្តើមគំនិតធ្វើច្បាប់ ។ តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ។ តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជ-រដ្ឋាភិបាល ។ ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយ -លក្ខណ៍អក្សរ ។ ចម្លើយខាងលើនេះត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ ។ រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញត្តិបន្ទោសតាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។ ក្នុងករណីនេះសូមធ្វើការកត់សម្គាល់ថា បើសិនរដ្ឋសភាទម្លាក់រដ្ឋាភិបាល ២ ដង ក្នុងរយៈពេល ១២ ខែ នាយករដ្ឋមន្ត្រីអាចស្នើព្រះមហាក្សត្ររំលាយរដ្ឋសភា ។ ព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា បន្ទាប់ពីទ្រង់បានបានការយល់ព្រមពីប្រធានរដ្ឋសភា ( មាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ ) ។

ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និង នៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ សូមធ្វើការកត់សម្គាល់ថា ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិនឹងត្រូវទុកជាអសារសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ ( មាត្រា ៩២ នៃរដ្ឋធម្មនុញ្ញ ) ។

**<u>ជំពូកទី៨</u> អំពីព្រឹទ្ធសភា** មាន ១៧ មាត្រា គឺពីមាត្រា ៩៩ ថ្មី ដល់ មាត្រា ១១៥ ថ្មី ដែលចែងថា ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ។ ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើន ស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។ សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។ សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប ។ រីឯសមាជិកព្រឹទ្ធសភាឯទៀតត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល ។ នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។ ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភានិងរដ្ឋាភិបាល ។ ព្រឹទ្ធសភាពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ។

**<u>ជំពូកទី៩</u> ថ្មី អំពីសមាជរដ្ឋសភា និង ព្រឹទ្ធសភា** មាន ០២ មាត្រា គឺពីមាត្រា ១១៦ ថ្មី ដល់ មាត្រា ១១៧ ថ្មី ដែលចែងថា ក្នុងករណីចាំបាច់ រដ្ឋសភា និង ព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។

សូមបញ្ជាក់ថា រដ្ឋសភាទើបតែបានអនុម័តច្បាប់រៀបចំអង្គការសមាជរដ្ឋសភា និង ព្រឹទ្ធសភា នៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១០ ។ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា

នេះត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រម ចុះថ្ងៃ ទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១១ ក្រោយពីក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ ក្នុងសេចក្ដីសម្រេចចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១ ។

**<u>ជំពូកទី១០</u> ថ្មី អំពីរាជរដ្ឋាភិបាល** មាន ១០ មាត្រា គឺពីមាត្រា ១១៨ ថ្មី ដល់ មាត្រា ១២៧ ថ្មី ដែលចែងថា គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។ គណៈរដ្ឋមន្ត្រី ត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក ។ សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភាអំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។ សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រីនិងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត ។

**<u>ជំពូកទី១១</u> អំពីអំណាចតុលាការ** មាន ០៨ មាត្រា គឺពីមាត្រា ១២៨ ថ្មី ដល់ មាត្រា ១៣៥ ថ្មី ដែលចែងថា អំណាចតុលាការជាអំណាចឯករាជ្យ គ្របដណ្ដប់ទៅលើរឿងក្ដីទាំងអស់ រួមទាំងរឿងក្ដីរដ្ឋបាលផង។ អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្ដីគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់។ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្ដី ។ គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬ នីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។ មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា ។

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្ដីស្នើថ្វាយព្រះមហា-ក្សត្រអំពីការតែងតាំងចៅក្រម និង ព្រះរាជអាជ្ញា ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដាក់វិន័យចំពោះចៅក្រម និង ព្រះរាជអាជ្ញា ។

**<u>ជំពូកទី១២</u> ថ្មី អំពីក្រុមប្រឹក្សាធម្មនុញ្ញ** មាន ០៩ មាត្រា គឺពីមាត្រា ១៣៦ ថ្មី ដល់ មាត្រា ១៤៤ ថ្មី នេះនឹងត្រូវបកស្រាយក្នុងចំណុចទី IV នៃបទឧទ្ទេសនាមស្ដីពីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**<u>ជំពូកទី១៣</u> ថ្មី អំពីការគ្រប់គ្រងរដ្ឋបាល** មាន ០២ មាត្រា គឺពីមាត្រា ១៤៥ ថ្មី និង មាត្រា ១៤៦ ថ្មី ដែលចែងថា ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

**<u>ជំពូកទី១៤</u> ថ្មី អំពីសមាជជាតិ** មាន ០៣ មាត្រា គឺពីមាត្រា ១៤៧ ថ្មី ដល់ មាត្រា ១៤៩ ថ្មី ដែលចែងថា សមាជជាតិបើកឱ្យប្រជារាស្ត្រជ្រាបដោយផ្ទាល់អំពីកិច្ចការផ្សេងៗដែលជាប្រយោជន៍ជាតិនិងលើកបញ្ហានិងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ ។

**<u>ជំពូកទី១៥</u> ថ្មី (ពីរ) អំពីអង្គការរៀបចំការបោះឆ្នោត** គឺមាន ០២ មាត្រា គឺមាត្រា ១៥០ ថ្មី (ពីរ) និងមាត្រា ១៥១ ថ្មី (ពីរ) ដែលចែងថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអង្គការដែលមានសមត្ថកិច្ចរៀបចំចាត់ចែង និង គ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាព ៩ រូប និង មានអាណត្តិ៥ឆ្នាំ ជ្រើសតាំងដោយរដ្ឋសភា ។

**<u>ជំពូកទី១៦</u> ថ្មី (ពីរ) អំពីអានុភាព ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ** មាន ០៤ មាត្រា គឺពីមាត្រា ១៥២ ថ្មី ( ពីរ មាត្រា ១៥០ ថ្មី ) ដល់ មាត្រា ១៥៥ ថ្មី ( ពីរ មាត្រា ១៥៣ ថ្មី ) ដែលចែងថា

រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ និង សេចក្ដីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

ការផ្ដើមគំនិតសើរើ ឬការផ្ដើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និង របស់ប្រធានរដ្ឋសភាតាមសេចក្ដីស្នើរបស់តំណាងរាស្ត្រមួយភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ការសើរើឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និង របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

**<u>ជំពូកទី១៧</u> ថ្មី អំពីអន្តរប្បញ្ញត្តិ** មាន ០៥ មាត្រា គឺពីមាត្រា ១៥៦ ថ្មី ( ពីរ មាត្រា ១៥៤ ថ្មី ) ដល់មាត្រា ១៦០ ថ្មី ( ពីរ មាត្រា ១៥៨ ថ្មី ) ដែលចែងថា រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឱ្យចូលជាធរមានភ្លាម ដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា ។ ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៣ ថ្មី និង ១៤ ។

## IV-សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នឯករាជ្យ និង អព្យាក្រឹត ដែលមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ។ ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យនិងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះ-ឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ( មាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ មាត្រា ២ និង មាត្រា ១៥ ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ) ។

### ១-ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់

#### ក-ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់

ច្បាប់រៀបចំអង្គការទាំងអស់ ក្រោយពីរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ត្រូវតែបញ្ជូនទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងត្រូវបានប្រកាសឱ្យប្រើ ( មាត្រា ១៦ ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ )។

បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ក៏ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងត្រូវប្រកាសឱ្យប្រើ ( មាត្រា ១៦ ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា -ធម្មនុញ្ញ ) ។

ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ឬ សមាជិករដ្ឋសភា ចំនួនមួយភាគដប់ អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យ ទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឱ្យប្រើ ( មាត្រា ១៧ ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ) ។

#### ខ-ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ក្រោយពេលដែលច្បាប់ប្រកាសឱ្យប្រើហើយ

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា

នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន សមាជិករដ្ឋសភាចំនួនមួយភាគដប់ ឬតុលាការអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ( មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ) ។

ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីអធម្មនុញ្ញភាពនៃច្បាប់ ទៅតាមរយៈព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ឬ តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភា ឬ សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ( មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ )។

បុគ្គលដែលពាក់ព័ន្ធក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះអាចស្នើអំពីអធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬ សេចក្តីសម្រេចរបស់ស្ថាប័ននានា ( ដូចជាព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ) ជូនតុលាការបាន ។ បើយល់ឃើញថា ការលើកឡើងនេះមានមូលដ្ឋានត្រឹមត្រូវ តុលាការនឹងបញ្ជូនពាក្យបណ្តឹងនេះទៅតុលាការកំពូល ។ តុលាការកំពូលបញ្ជូនបណ្តឹងនេះទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ បើយល់ឃើញថាបណ្តឹងតវ៉ានេះសមហេតុផល ( មាត្រា ១៩ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ) ។

**២-ការបកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់**

មាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់ តាមសំណើពីព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ឬតំណាងរាស្ត្រចំនួនមួយភាគដប់នៃរដ្ឋសភា ។

ប្រជារាស្ត្រក៏មានសិទ្ធិសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយច្បាប់ដែរ តាមរយៈ ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ឬ ប្រធានព្រឹទ្ធសភា សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ( មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ) ។

**៣ -ការដោះស្រាយវិវាទនៃការបោះឆ្នោត**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចចំពោះបណ្តឹងទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ( មាត្រា ២៥ ថ្មី នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ) ។

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនិងសម្រេចលើបណ្តឹងរបស់គណបក្សនយោបាយដែលក្រសួងមហាផ្ទៃបានបដិសេធមិនព្រមចុះបញ្ជីគណបក្សនយោបាយ ។

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនិងសម្រេចលើបណ្តឹងតវ៉ារបស់បុគ្គល ឬ គណបក្សដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទំនាក់ទំនងនឹងបញ្ជីរាយនាមបេក្ខជន ការចុះឈ្មោះបោះឆ្នោត ការបាត់ឈ្មោះ ការជំទាស់ និង ការចុះឈ្មោះ ឬ ការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោត ព្រមទាំងការឃោសនាបោះឆ្នោត ។

ចំពោះលទ្ធផលនៃការបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនិងសម្រេចលើបណ្តឹងរបស់បុគ្គល ឬ គណបក្សនយោបាយដែលមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត ឬ បណ្តឹងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលសម្រេចបដិសេធការតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ។

បណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោតត្រូវធ្វើឡើងរយៈពេល ៧២ ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ន ឬ បន្ទាប់ពីការទទួលការជូនដំណឹងនៃសេចក្តីសម្រេចបដិសេធរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងសមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោតនេះ ក្រុមប្រឹក្សាធម្មនុញ្ញមានតួនាទីដូចជាតុលាការ ដោយប្រើនីតិវិធីឲ្យភាគីផ្តល់ភស្តុតាង ដោយស្តាប់ចម្លើយសាក្សី ដោយធ្វើការស្រាវជ្រាវ ស៊ើបអង្កេត និងសួរដេញដោលចំពោះមុខក្នុងសវនាការជាសាធារណៈ មុននឹងសម្រេចសេចក្តី ។

ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៣ កន្លងមកនេះ ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលបណ្តឹងតវ៉ានឹងសេចក្តីជូនដំណឹង និង សេចក្តីសម្រេចរបស់គណៈ - កម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប ) ពីតំណាងគណបក្សសង្គ្រោះជាតិ និង គណបក្សប្រជាជនកម្ពុជា សរុប ៤២ ពាក្យបណ្តឹងតវ៉ា បែងចែកជាតាមដំណាក់កាលនៃការបោះឆ្នោត មានដូចខាងក្រោម ៖

ក-ដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោត មាន ០៣ បណ្តឹងតវ៉ា និងបានចេញសេចក្តីសម្រេចចំនួន ០៣ សម្រេចដោយសវនាការជាសាធារណៈ ។

ខ-ដំណាក់កាលឃោសនាបោះឆ្នោត មាន ១២ បណ្តឹងតវ៉ា ។ ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសម្រេច ០១ និង សេចក្តីជូនដំណឹង ១១ សម្រេចក្នុងកិច្ចប្រជុំពេញអង្គ ។

គ-ដំណាក់កាលថ្ងៃបោះឆ្នោត គឺថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៣ មាន ១២ បណ្តឹងតវ៉ា ។ ក្រុម - ប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីជូនដំណឹង ១២ សម្រេចក្នុងកិច្ចប្រជុំពេញអង្គ ។

ឃ-ដំណាក់កាលក្រោយពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រកាសលទ្ធផលបណ្តោះ-អាសន្ននៃការបោះឆ្នោតមាន ១៥ បណ្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ។ ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសម្រេចចំនួន ១៥ ក្នុងនោះមាន ១១ សេចក្តីសម្រេច គឺសម្រេចក្នុងកិច្ចប្រជុំពេញអង្គ និង ០៤ សេចក្តីសម្រេច គឺសម្រេចដោយបើកសវនាការជាសាធារណៈ ។ ០៤ សេចក្តីសម្រេចខាងក្រោយនេះ គឺករណីតវ៉ានៅមណ្ឌលខេត្តក្រចេះ ខេត្តសៀមរាប ខេត្តបាត់ដំបង និង ខេត្តកណ្តាល ហើយក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចឲ្យគណៈ - កម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព " ក " មួយចំនួនផង ដើម្បីត្រួតពិនិត្យ ។

ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យ និង សម្រេចលើបណ្តឹងតវ៉ាទាំង ៤២ ដោយផ្អែកលើមូលដ្ឋានគតិយុត្តទាំងស្រុង រក្សាបាននូវអនាគតិ ឬ ភាពមិនលំអៀង និង សម្រេចដោយសំឡេងឯកច្ឆន្ទគ្រប់ករណីទាំងអស់ និង ដោយមនសិការហ្មឹងហ្មត់ទាំងអស់គ្នា ។

**៤-ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចពីរផ្សេងទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ**

- ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចថ្វាយមតិដល់ព្រះមហាក្សត្រ នៅពេលដែលព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ( មាត្រា ១៤៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ) ។

- ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចលើមោឃភាពនៃការអនុម័តទាំងឡាយរបស់រដ្ឋសភាដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលនាំឲ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬ ការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ ( មាត្រា ៩២ នៃរដ្ឋធម្មនុញ្ញ ) ។

ជាទីបញ្ចប់សូមគូសបញ្ជាក់ថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា មានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ បទប្បញ្ញត្តិណាមួយនៃច្បាប់ដែលក្រុមប្រឹក្សាធម្មនុញ្ញសម្រេចថា មិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសឲ្យប្រើ ឬ យកទៅអនុវត្តបានឡើយ ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ជូនប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និង ប្រធានតុលាការកំពូល និងចុះផ្សាយក្នុងរាជកិច្ច ។

ខ្ញុំសូមបញ្ចប់បទឧទ្ទេសនាមរបស់ខ្ញុំត្រឹមនេះ សូមថ្លែងអំណរគុណដល់ការយកចិត្តទុកដាក់ស្តាប់។

**សូមអរគុណ !**